# អង្គជំនុំជម្រះកោះហៅសាក្សីចុងក្រោយរបស់ជនជាប់ចោទ ឡើងឈរចំពោះមុខអង្គជំនុំជម្រះ

ម៉ៃ ឃើល សាលីបា

ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ ២០០៩

ប្រែសម្រួលដោយ គឹម ម៉ារីយ៉ាន

ថ្ងៃនេះនៅក្នុងសវនាការរបស់ កាំង ហ្កេកអ៊ាវ ហៅ ឌុច អង្គជំនុំជម្រះបានទទួលនូវសក្ខីកម្មរបស់សក្សីពីររូប មុនពេលកោះហៅ ឌុច ឲ្យក្រោកឈរ ដើម្បីបន្តការសាកសួរអំពីចរិតលក្ខណៈរបស់ ឌុច ។ គ្រីស្តូហ្វឺ ឡាប៉ែល ជាអាចារ្យម្នាក់ដែលបានប្រសិទ្ធីឲ្យ ឌុច នៅក្នុងឆ្នាំ១៩៩៦ បានផ្តល់សក្ខីកម្មអំពីការផ្លាស់ប្តូរទៅកាន់សាសនាគ្រិស្តរបស់ ឌុច ។ បន្ទាប់មកក្នុងថ្ងៃនោះ ស្តេហ្វិន ហាស្ទែរល អ្នកនៅរស់រានមានជីវិតនៃជំរំឃុំខ្លួនរបស់ពួកណាស៊ីស និងជាមនុស្សម្នាក់ នៅក្នុងចំណោមអ្នកព្រាងលើសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស បានផ្តល់សក្ខីកម្មអំពីលទ្ធភាពនៃការផ្សះផ្សានៅសម័យក្រោយជម្លោះដូចជានៅកម្ពុជាជាដើម ។

គ្រីស្តូហ្វឺ ឡាប៉ែល បានជួប ឌុច នៅក្នុងខែធ្នូ ឆ្នាំ១៩៩៥ នៅពេលដែល ឌុច បាននឹងកំពុងស្វែងរកផ្លាស់ប្តូរទៅសាសនាគ្រិស្ត ហើយបានបញ្ចូលគាត់ទៅក្នុងសាសនាគ្រិស្តនៅថ្ងៃទី៦ ខែមករា ឆ្នាំ១៩៩៦ ។ គាត់បានពណ៌នាថា ឌុច គឺជាមនុស្សម្នាក់ដែលចិត្តល្អ ហើយជាមនុស្សម្នាក់មានភាពរាក់ទាក់ជាមួយនឹង«ទឹកចិត្តជាអ្នកបម្រើ» ។ គាត់មិនបានដឹងពីការជាប់ទាក់ទងរបស់ ឌុច ជាមួយនឹងខ្មែរក្រហមកាលពីអតីតកាលនោះទេ ។ ប៉ុន្តែ គាត់បានដឹងថា ឌុច ជាមនុស្សម្នាក់ ដែលរស់នៅក្នុងភាពផងឹតគ្មានភាពសប្បាយរីករាយ គ្មានសេចក្តីស្រលាញ់ឬក៏បំណងប្រាថ្នាអ្វីទាំងអស់ ។ គ្រីស្តូហ្វឺ ឡាប៉ែល បានសិក្សាលើកដំបូងលើអត្តសញ្ញាណរបស់ ឌុច នៅក្នុងខែមេសា ឆ្នាំ១៩៩៩ ។ ការប្រកាសនេះបានធ្វើឲ្យគាត់ភ្ញាក់ផ្អើល ប៉ុន្តែ គាត់បានរៀបរាប់ពីអារម្មណ៍នៃភាពសប្បាយរីករាយយ៉ាងខ្លាំង ពីការយល់ដឹងរបស់គាត់ថា ព្រះបានផ្លាស់ប្តូរឃាតករម្នាក់ទៅជាមនុស្សម្នាក់ដែលមានជំនឿ ។ ព្រះរាជអាជ្ញាបានជំទាស់ទៅនឹងភាពស្មោះត្រង់ក្នុងការចូលសាសនារបស់ ឌុច ដោយលើកនូវយោបល់ថា វាមិនមានអ្វីក្រៅពីការសំអាង និងឱកាសនៃការសម្រេចចិត្តដែលធ្វើឲ្យ ឌុច ទទួលបាននូវអត្ថប្រយោជន៍មួយរំពេច និងការលើកលែងទោសដោយឥតមានលក្ខខណ្ឌរបស់ព្រះក្នុងសាសនាគ្រិស្ត ។ នៅក្នុងសាសនាព្រះពុទ្ធ

អំពើបាបរបស់ ឌុច នឹងនាំគាត់ទៅកាន់បាបកម្ម ហើយបាបកម្មនេះនឹងស្ថិតនៅជាប់ជាមួយគាត់រហូតដល់ការចាប់កំណើតថ្មីរបស់គាត់ ។ ក៏ប៉ុន្តែ នៅក្នុងសាសនាគ្រិស្ត អំពើបាបរបស់មនុស្សម្នាក់ត្រូវបានលើកលែងទោសនៅពេលលាងបាបដរាបណាការចូលសាសនាគ្រិស្តគឺពិតប្រាកដ ។

ព្រះរាជអាជ្ញា មានបំណងធ្វើឲ្យកាន់តែមានវិមតិទៅលើភាពពិតប្រាកដ នៃការចូលសាសនាគ្រិស្តរបស់ ឌុច ដោយការអះអាងថា ឌុច បានចូលសាសនាគ្រិស្តឆាប់រហ័សពេក និងមិនមានការសិក្សាឲ្យបានល្អិតល្អន់អំពីសាសនានេះឡើយ ។ មេធាវីការពារក្តីបានឆ្លើយតបថា វាគឺជាចេតនាយ៉ាងពិតប្រាកដរបស់មនុស្សម្នាក់ ហើយមិនមែនរយៈពេលនៃការសិក្សារបស់ពួកគេ ដែលអាចជាឧបសគ្គក្នុងការចូលសាសនាដោយស្មោះត្រង់នោះទេ ។ គ្រីស្តូហ្វឺ ឡាប៉ែល យល់ស្របនឹងមេធាវីការពារក្តីថាការចូលសាសនារបស់ ឌុច គឺស្មោះត្រង់ ហើយចេញពីចិត្តពិតប្រាកដ ។

នៅក្នុងការចាប់ផ្តើមនៃការប្រជុំនៅពេលរសៀល ស្តេហ្វិន ហាស៊ែរល អ្នករស់រានមានជីវិតពីជំរំរបស់ពួកណាស៊ីស និងជាមនុស្សម្នាក់ នៅក្នុងចំនោមអ្នកព្រាងសេចក្តីប្រកាសជាសកល ស្តីពីសិទ្ធិមនុស្សបានផ្តល់សក្ខីកម្មអំពីលទ្ធភាពនៃការផ្សះផ្សា នៅសម័យក្រោយជម្លោះដូចជានៅប្រទេសកម្ពុជាជាដើម ។ ស្តេហ្វិន ហាស៊ែរល គឺធ្លាប់ជាសាក្សីសាលាជម្រះក្តីនៅ ណូរ៉ឺមប៊ឺក និងបានផ្តល់សក្ខីកម្មថាសាលាជម្រះក្តីទាំងអស់នោះមានផលជាវិជ្ជមាន ចំពោះការផ្សះផ្សារវាងក្រុមនិយាយភាសាបារាំង និងក្រុមនិយាយភាសាអាឡឺម៉ង់ ។ គាត់បានអះអាងថា ការបង្កើតឡើងនូវប្រវត្តិសាស្ត្រនៃការពិត សាលាជម្រះក្តីនៅ អ.វ.ត.ក នឹងមានផលជាវិជ្ជមានស្រដៀងគ្នាដែរចំពោះការផ្សះផ្សានៅក្នុងប្រទេសកម្ពុជា ។ លោក ហាស៊ែរល ក៏បានលើកឡើងដែរថា គំនិតនៃការអភ័យទោសឲ្យនោះ គឺអាស្រ័យទៅលើជនរងគ្រោះ ហើយការទទួលស្គាល់កំហុសរបស់ជនល្មើសមិនប្រាកដថា គ្រប់គ្រាន់សម្រាប់ឲ្យជនរងគ្រោះអភ័យទោសឲ្យនោះទេ ។ នៅក្នុងករណីនេះគាត់បានពន្យល់ថា ការផ្សះផ្សានៅក្នុងសង្គមអាចនឹងនៅតែសម្រេចបាននៅក្នុងទំរង់សន្តិសហវិជ្ជមានដែលជនរងគ្រោះ និងជនល្មើសអាចរងនៅជាមួយគ្នាបានដោយមិនមានជម្លោះ ។

នៅពេលរសៀលបន្តិច តុលាការបានកោះហៅ ឌុច ម្តងទៀតមកឈរជាលើកទីបី ដើម្បីសាកសួរអំពីចរិតលក្ខណៈ ឌុច ។ (អង្គជំនុំជម្រះ បានជ្រើសរើសពន្លឿនដំណើរការជាជាងការបន្តនៅក្នុងការកោះហៅមកឈរចំពោះមុខតុលាការជារាល់ពេលដែលសាក្សីសំរាក) ។ លោកចៅក្រម ឡាវ៉ែន បានបន្តការសួរសំនួរទៅកាន់ ឌុច ដោយផ្តោតទៅលើទំនាក់ទំនងរបស់ ឌុច ជាមួយនឹងបងថ្លៃប្រុស ។ រឿងដែលគួរឲ្យចាប់អារម្មណ៍នោះ គឺបងថ្លៃប្រុសម្នាក់របស់ ឌុច ត្រូវបានជាប់ឃុំឃាំងនិងសម្លាប់នៅគុកទួលស្លែង (មន្ទីរស-២១) ។

បងថ្លៃប្រុសរបស់ ឌុច ត្រូវបានចាប់ខ្លួនដោយកម្មាភិបាលថ្នាក់តំបន់ នៅខណៈពេលបម្រើការជាអនុប្រធានមន្ទីរសន្តិបាលនៅខេត្តកំពង់ធំ ។ ត្រង់ចំណុចនេះ គាត់បានផ្ញើសំបុត្រមួយច្បាប់ឲ្យ ឌុច ដើម្បីសុំជំនួយ ។ ឌុច បានផ្តល់សក្ខីកម្មថា គាត់ចង់ជួយបងថ្លៃប្រុសរបស់គាត់ ប៉ុន្តែការបញ្ជាឲ្យចាប់នោះមិនអាចប្រឆាំងបានឡើយ ។ លើសពីនេះទៅទៀត កិច្ចការដ៏ធំរបស់គាត់ គឺបក្សបង្គាប់ឲ្យគាត់បែកវំលែកសំបុត្រជាមួយថ្នាក់លើគាត់គឺ សុន សេន ។ ដូចច្នេះបងថ្លៃប្រុសរបស់ ឌុច ត្រូវបានអនុញ្ញាតឲ្យ ឌុច ជាអ្នកសួរចម្លើយដោយផ្ទាល់ ។ ក៏ប៉ុន្តែគាត់ចាប់ផ្តើមបង្កើតបញ្ហាបន្ទាប់ពីការសួរចម្លើយ ។ ដោយថាហេតុ ឌុច បានសម្រេចចិត្តដោយគ្មានជម្រើសក្នុងការចាប់បងថ្លៃប្រុសបញ្ជូនទៅស-២១ ។ តើគាត់ពិតជាបានធ្វើដូចនេះមែន ឌុច បានអះអាងថា គាត់ និងគ្រួសាររបស់គាត់អាចត្រូវបានចាប់ខ្លួនដោយថាហេតុ ដោយសារអំពើរបស់បងថ្លៃប្រុសគាត់ ។

ឌុច បានពន្យល់ថា ផ្ទុយពីការអនុវត្តធម្មតា បងស្រីគាត់ និងកូនៗត្រូវបានបំបែកនៅពេលដែលបងថ្លៃប្រុសត្រូវចាប់ខ្លួន ពីព្រោះ ឌុច ការពារក្រុមគ្រួសាររបស់បងស្រី ។ ឌុច មានជំនឿថា ប្រសិនបើបងស្រីត្រូវបានចាប់ខ្លួន ឌុច ខ្លួនឯងផ្ទាល់ក៏អាចនឹងត្រូវជាប់ទាក់ទងដែរ ។ សម្រាប់មូលហេតុនេះ ឌុច បានកំណត់ថា គាត់មានឱកាសល្អជាងការនៅរស់រានមានជីវិតទៀត ដោយការពារគ្រួសារបងស្រីប្រសើរជាងចាប់ពួកគាត់ ។ ហេតុដូច្នោះ ឌុច បានធានាចំពោះបងស្រីគឺជាសមាជិកដ៏ស្មោះត្រង់របស់បក្ស ហើយនាំគាត់ទៅធ្វើការនៅស-២១ ។